# សេចក្ដីប្រោសលោះ

*ដោយអែលឌើរ ឡឺហ្គ្រង់ អ័រ ខឹតធីស ជុញ្ញ័រ*
*នៃពួកចិតសិបនាក់*

មានសេចក្ដីយោងជាច្រើនត្រូវបានធ្វើឡើង ចំពោះព្រះនាមនៃព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ។ ព្រះនាមទាំងនេះផ្ដល់ឲ្យយើងនូវការយល់ដឹងក្នុងទិដ្ឋភាពខុសគ្នា ចំពោះបេសកកម្មដែលធ្វើឲ្យធូនរបស់ព្រះអម្ចាស់។ ឧទហរណ៍ ងារជា « ព្រះអង្គសង្គ្រោះ » ។ យើងរាល់គ្នាបានយល់ពីអត្ថន័យនៃពាក្យថាត្រូវបានសង្គ្រោះ ពីព្រោះយើងម្នាក់ៗត្រូវបានសង្គ្រោះឲ្យរួចផុតពីអ្វីមួយ នៅពេលណាមួយ ។ កាលពីក្មេង ពេលប្អូនស្រីខ្ញុំ ហើយនិងខ្ញុំកំពុងតែលេងនៅលើកូនទូកតូចមួយ ដែលបណ្ដែតនៅលើស្ទឹង ហើយដោយមិនបានគិតគូរវែងឆ្ងាយ យើងបានចាកចេញពីកន្លែងដែលមានសុវត្ថិភាព ហើយចរន្តទឹកហូរបានទាញយើងទៅកន្លែងគ្រោះថ្នាក់ ។ ដោយបានឮសម្រែកយើង ឪពុកយើងក៏បានរត់មកជួយសង្គ្រោះយើង ចេញពីគ្រោះថ្នាក់នោះ ។ ពេលខ្ញុំគិតពីការសង្គ្រោះ  គឺខ្ញុំគិតដល់បទពិសោធន៍នោះ ។

ងារជា « ព្រះអង្គប្រោសលោះ » ផ្ដល់នូវការយល់ដឹងស្រដៀងគ្នានេះដែរ ។ « ការប្រោសលោះ »  គឺជាការស្រោចស្រង់ ឬការបង់ថ្លៃលោះ ។ ក្នុងបញ្ហាផ្នែកច្បាប់ ទ្រព្យសម្បត្តិគឺត្រូវបានលោះមកវិញ ដោយការបង់ប្រាក់សងដល់ចំពោះការដាក់បញ្ចាំ ឬការដាក់ធានាផ្សេងទៀត ។  ក្នុងសម័យព្រះគម្ពីរសញ្ញាចាស់ ក្រឹត្យវិន័យ ម៉ូសេ បានផ្ដល់នូវរបៀបផ្សេងៗពីគ្នាដែលអ្នកបម្រើ និងទ្រព្យសម្បត្តិអាចមានសេរីភាព ឬអាចលោះមកវិញ ដោយការបង់ប្រាក់ ( សូមមើលលេវីវិន័យ 25:31 )  ។

ការប្រើពាក្យ *ប្រោសលោះ* ក្នុងបទគម្ពីរដ៏ចំណានមួយគឺទាក់នឹងការរំដោះកូនចៅអ៊ីស្រាអែលចេញពីទាសភាពខ្លួនក្នុងប្រទេសអេស៊ីព្ទ។ បន្ទាប់ពីការរំដោះនោះមក ម៉ូសេបានប្រាប់ ពួកគេថា « ដោយព្រោះព្រះអម្ចាស់ទ្រង់ស្រឡាញ់អ្នករាល់គ្នា...បានជា [ ទ្រង់ ]នាំអ្នកចេញមក ដោយព្រោះទ្រង់មានព្រះចេស្ដា ហើយបានលោះអ្នកពីផ្ទះពួកបាវបម្រើ គឺពីកណ្ដាប់ដៃនៃផារ៉ោនជាស្តេចស្រុងអេស៊ីព្ទមក » ( ចោទិយកថា 7:8 ) ។

ប្រធានបទពីព្រះយេហូវ៉ាដែលបានប្រោសលោះដល់ប្រជាជនអ៊ីស្រាអែ-លចេញពីទាសភាព គឺត្រូវបានលើកឡើងជាច្រើនដងនៅក្នុងព្រះគម្ពីរទាំងឡាយ ។  ជារឿយៗ ការណ៍នេះធ្វើឡើងដើម្បីឲ្យមនុស្សនឹកចាំពីក្ដីសន្ដោសរបស់ព្រះអម្ចាស់ នៅក្នុងការរំដោះដល់កូនចៅនៃអ៊ីស្រាអែលពីពួកអេស៊ីព្ទ។ តែការណ៍នោះក៏ត្រូវបានធ្វើឡើង ដើម្បីបង្រៀនពួកគេថានឹងមានការប្រោសលោះដ៏សំខាន់មួយទៀតដល់សាសន៍អ៊ីស្រាអែល ។ លីហៃបានបង្រៀនថា ៖  « ហើយព្រះមែស៊ីនឹងយាងមក នៅកាលដ៏ពេញកំណត់ ដើម្បីទ្រង់អាចប្រោសលោះកូនចៅមនុស្សឲ្យរួចពីការធ្លាក់ » (នីហ្វៃទី 2 2:26) ។

អ្នកតែងបទទំនុកដំកើងបានសរសេរថា ៖ « ប៉ុន្តែព្រះទ្រង់នឹងលោះព្រលឹងខ្ញុំ ឲ្យរួចពីអំណាចនៃស្ថានឃុំព្រលឹងមនុស្សស្លាប់នោះវិញ » ( ទំនុកដំកើង 49:15 ) ។

ព្រះអម្ចាស់បានប្រកាសតាមរយៈអេសាយថា ៖ « យើងបានលុបអំពើរំលងរបស់អ្នកចេញ ដូចជាពពកយ៉ាងក្រាស់ និងអំពើបាបអ្នកដូចជាពពកផងៈ ចូរវិលមកឯយើងវិញ ពីព្រោះយើងបានលោះអ្នកហើយ » ( អាសាយ 44:22 ) ។

ពិតណាស់ ការប្រោសលោះដែលបានលើកឡើងនៅក្នុងបទគម្ពីរទាំងបីនេះគឺជាដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។ នេះជា « ការប្រោសលោះដ៏ឧត្តុង្គឧត្ដម » ដែល បានប្រទានមកដោយព្រះដ៏ជាទីស្រឡាញ់របស់យើង (ទំនុកដំកើង 130:7) ។ មិនដូចជាការប្រោសលោះតាមក្រិត្យវិន័យរបស់ម៉ូសេ ឬតាមការចាត់ចែងតាមច្បាប់នាសម័យកាលនេះទេ ការប្រោសលោះនេះពុំមែនកើតចេញពី « របស់ពុករលួយ ដូចជាប្រាក់ឬមាស » ឡើយ ( ពេត្រុសទី 1 1:18 )។ « នៅក្នុង[ ព្រះគ្រីស្ទ ] យើងបាន សេចក្ដីប្រោសលោះដោយសារព្រះលោហិតទ្រង់ គឺជាសេចក្ដីប្រោសឲ្យរួចពីទោស តាមព្រះ គុណដ៏ធ្ងន់ក្រៃលែងនៃទ្រង់ » ( អេភេសូរ 1:7 ) ។  ប្រធានយ៉ូហានថៃលឺបានបង្រៀនថា ព្រោះតែពលិកម្មរបស់ព្រះប្រោសលោះនោះ « បំណុលត្រូវបានបង់សេចក្ដីប្រោសលោះត្រូវបានធ្វើឡើង សេចក្ដីសញ្ញាត្រូវបានបំពេញ យុត្តិធម៌ត្រូវបានស្កប់ស្កល់ ព្រះហឫទ័យរបស់ព្រះត្រូវបានសម្រេច ហើយនិងអំណាចទាំងអស់គឺ... ត្រូវបានប្រគល់ទៅក្នុងព្រះហស្តនៃព្រះរាជបុត្រារបស់ព្រះ » (*Teachings of Presidents of the Church: John Taylor* [2001] ទំព័រ 44)។

ឥទ្ធិពលនៃការប្រោសលោះនេះ រួមទាំងការយកឈ្នះលើការស្លាប់ខាងរូបកាយសម្រាប់កូនចៅរបស់ព្រះទាំងអស់ ។  គឺថា សេចក្ដីស្លាប់ខាងរូបកាយគឺត្រូវបានយកឈ្នះ ហើយមនុស្សគ្រប់រូបនឹងត្រូវបានរស់ឡើងវិញ ។ ទិដ្ឋភាពមួយទៀតនៃការប្រោសលោះនេះ ដោយព្រះគ្រីស្ទគឺជាជ័យជំនះលើការស្លាប់ខាងវិញ្ញាណ ។  តាមរយៈការរងទុក្ខនិងការសុគតរបស់ទ្រង់ ព្រះគ្រីស្ទបានបង់ថ្លៃចំពោះអំពើបាបនៃមនុស្សលោកតាម លក្ខខណ្ឌនៃការប្រែចិត្តរបស់បុគ្គលម្នាក់ៗ ។

ដូច្នេះ បើយើងប្រែចិត្ត យើងអាចទទួលបានការអភ័យទោសពីអំពើបាបយើង ហើយ ព្រះប្រោសលោះរបស់យើងបានបង់ថ្លៃចំពោះអំពើបាបរបស់យើងរួចហើយ ។ នេះជាដំណឹងល្អសម្រាប់យើងគ្រប់រូប « ពីព្រោះគ្រប់គ្នាធ្វើបាប ហើយខ្វះមិនដល់សិរីល្អនៃព្រះ » ( រ៉ូម 3:23 ) ។ អស់អ្នកដែលបែរចិត្តចេញពីផ្លូវនៃភាពសុចរិត ពិតជាត្រូវការការប្រោសលោះនេះជាខ្លាំង ហើយបើពួកគេប្រែចិត្តទាំងស្រុង នោះពួកគេនឹងទទួលផលរបស់ខ្លួន ។ តែអស់អ្នកដែលបានខិតខំរស់នៅក្នុងជីវិតមួយដ៏ល្អ ក៏ត្រូវការការប្រោសលោះនេះខ្លាំងដែរ ត្បិតគ្មាននរណាម្នាក់អាចចូលទៅឯវត្តមានរបស់ព្រះវរបិតា ដោយគ្មានជំនួយពីព្រះគ្រីស្ទបានឡើយ ។ ដូច្នេះហើយ ការប្រោសលោះដ៏ឧត្តុង្គឧត្តមនេះ ធ្វើឲ្យក្រឹត្យវិន័យនៃយុត្តិធម៌ និងក្រឹត្យវិន័យនៃក្ដីមេត្តាករុណាមានភាពស្កប់ស្កល់ នៅក្នុងជីវិតនៃអស់អ្នកដែលប្រែចិត្ត ហើយដើរតាមព្រះគ្រីស្ទ ។

« ឱ !ការរចនាដ៏ធំនៃការប្រោសលោះ ដែលសេចក្ដីយុត្តិធម៌ សេចក្ដីស្រឡាញ់ និងសេចក្ដីមេត្តាករុណាជំនួបគ្នាក្នុងភាពសុខដុមដ៏ទេវភាព មានភាពធំអនេក រុងរឿង និងពេញលេញអ្វីម្ល៉េះទេ » ( «ឱប្រាជ្ញា និងក្ដីស្រឡាញ់ដ៏ធំអស្ចារ្យ » ទំនុកដំកើង និងចម្រៀងកុមារាកុមារី ទំព័រ 19 ) ។

ប្រធាន ប៊យដ៍ យេ ផាកកឺ បានបង្រៀនថា ៖ « មានព្រះប្រោលោះ និងព្រះសង្គ្រួបសង្គ្រួមមួយអង្គ ដែលបានស្ម័គ្រចិត្ត និងមានលទ្ធភាពដើម្បីទាមទាររកសេចក្ដីយុត្តិធម៌ ហើយប្រទាននូវសេចក្ដីមេត្តាកុរណាដល់អស់អ្នកដែលប្រែចិត្ត » ( «The Mediator » *Ensign* ខែ ឧសភា ឆ្នាំ 1977  ទំព័រ 56 ) ។

ព្រះគម្ពីរ អក្សរសាស្ត្រ និងបទពិសោធន៍ទាំងឡាយនៃជីវិតគឺពេញដោយដំណើររឿងនៃការប្រោសលោះ ។ តាមរយៈព្រះគ្រីស្ទ មនុស្សលោកពិតជាអាចផ្លាស់ប្ដូរជីវិតរបស់ខ្លួន ហើយទទួលយកការប្រោសលោះបាន ។ ខ្ញុំចូលចិត្តដំណើររឿងនៃការប្រោសលោះទាំងនេះណាស់ ។

ខ្ញុំមានមិត្តម្នាក់ដែលមិនបានធ្វើតាមការបង្រៀននៃសាសនាចក្រ នៅក្នុងយុវវ័យរបស់គាត់ឡើយ ។ ពេលគាត់ពេញវ័យ គាត់បានដឹងពីអ្វីដែលគាត់បានបាត់បង់ ដោយការមិនបានរស់នៅតាមដំណឹងល្អ ។ គាត់បានប្រែចិត្ត ហើយបានផ្លាស់ប្ដូរជីវិត ហើយបានបូជាខ្លួន ចំពោះការរស់នៅដោយសុចរិត ។ ប៉ុន្មានឆ្នាំក្រោយមក បន្ទាប់ពីការសេពគប់កាលពីវ័យក្មេងរបស់យើង មានថ្ងៃមួយ ខ្ញុំបានជួបគាត់នៅក្នុងព្រះវិហារបរិសុទ្ធ ។ ពន្លឺនៃដំណឹងល្អបានជះរស្មីនៅក្នុងកែវភ្នែករបស់គាត់ ហើយខ្ញុំបានមានអារម្មណ៍ថា គាត់ជាសមាជិកសាសនាចក្រដែលមានការលះបង់ខ្ពស់ ដែលកំពុងខិតខំរស់នៅដោយពេញលេញតាមដំណឹងល្អ ។ រឿងរបស់គាត់ជាដំណើររឿងនៃការប្រោសលោះ ។

មានគ្រាមួយ ខ្ញុំបានសម្ភាសស្ត្រីម្នាក់ដែលមានកំហុសក្នុងអំពើបាបដ៏ធ្ងន់ធ្ងរមួយ ដើម្បីទទួលបុណ្យជ្រមុជទឹក ។ ក្នុងពេលធ្វើការសម្ភាសន៍នោះ ខ្ញុំបានសួរ ដើម្បីបញ្ជាក់ថា គាត់បានយល់ ថាគាត់មិនអាចធ្វើអំពើបាបដដែលនោះបានទៀតឡើយ ។ គាត់បានតបទាំងអារម្មណ៍ក្ដុកក្ដួលថា « លោកប្រធានអើយ ខ្ញុំមិនអាចធ្វើអំពើបាបនោះទៀតទេ ។ នេះជាមូលហេតុដែលខ្ញុំចង់ទទួលបុណ្យជ្រមុជទឹក---ដើម្បីសំអាតខ្ញុំពីឥទ្ធិពលនៃអំពើបាបដ៏សាហាវនោះ  » ។ នេះជាដំណើររឿងនៃការប្រោសលោះ ។

ពេលខ្ញុំទៅចូលរួមសន្និសីទស្តេកនានា និងការប្រជុំផ្សេងទៀតនៅប៉ុន្មានឆ្នាំថ្មីៗនេះ ខ្ញុំបាននាំយកការអំពាវនាវរបស់ប្រធានម៉នសុន ដើម្បីទៅជួយសង្គ្រោះដល់មាជិកសាសនាចក្រដែលមិនសូវសកម្ម ។ នៅក្នុងសន្និសីទស្តេកមួយ ខ្ញុំបានប្រាប់ពីដំណើររឿងមួយនៃសមាជិកមិនសូវសកម្មម្នាក់ដែលបានត្រឡប់មកសកម្មវិញ បន្ទាប់ពីប៊ីស្សព និងពួកអ្នកដឹកនាំដទៃទៀតបានទៅសួរសុខទុកគាត់នៅផ្ទះ ហើយបានប្រាប់គាត់ថា គាត់ជាមនុស្សសំខាន់ហើយបានហៅគាត់ឲ្យបម្រើនៅក្នុងវួដ ។ បុរសនៅក្នុងរឿងនេះមិនត្រឹមតែបានទទួលការហៅបម្រើប៉ុណ្ណោះទេ តែថែមទាំងបានផ្លាស់ប្ដូរជីវិត និងទម្លាប់របស់ខ្លួន ហើយបានក្លាយជាសមាជិកសកម្មយ៉ាងពេញលេញនៅក្នុងសាសនាចក្រវិញ ។

មានមិត្តខ្ញុំម្នាក់បានចូលរួមការប្រជុំដែលខ្ញុំបានលើកឡើងពីដំណើររឿងនោះ ។ ទឹកមុខរបស់គាត់បានផ្លាស់ប្ដូរ កាលរឿងនោះត្រូវបានលើកឡើង ។ គាត់បានផ្ញើអ៊ីមែលមួយមកខ្ញុំនៅថ្ងៃបន្ទាប់ ដោយប្រាប់ខ្ញុំថា អារម្មណ៍ក្ដុកក្ដួលរបស់គាត់បានភ្ជាប់ទៅនឹងរឿងនោះ ដោយព្រោះតែរឿងឪពុកក្មេកគាត់ដែលបានត្រឡប់មកសកម្មវិញក្នុងសាសនាចក្រ គឺស្រដៀងគ្នានឹងរឿងដែលខ្ញុំបានប្រាប់ ។ គាត់បានប្រាប់ខ្ញុំថា ដោយសារការទៅសួរសុខទុករបស់ប៊ីស្សព និងការអញ្ជើញឲ្យបម្រើស្រដៀងគ្នានេះនៅក្នុងសាសនាចក្រ នោះឪពុកក្មេករបស់គាត់បានពង្រឹងជីវិត និងទីបន្ទាល់របស់ខ្លួនសារជាថ្មីធ្វើការផ្លាស់ប្ដូរដ៏ធំនៅក្នុងជីវិតរបស់គាត់ ហើយបានទទួលយកការហៅនោះ ។ បុរសដែលបានធ្វើឲ្យសកម្មឡើងវិញរូបនោះ ឥឡូវ មានកូនចៅ 88 នាក់ ដែលជាសមាជិកសកម្មនៅក្នុងសាសនាចក្រ ។

ពីរបីថ្ងៃក្រោយទៀត នៅក្នុងការប្រជុំមួយ ខ្ញុំបាននិយាយប្រាប់ពីដំណើររឿងទាំងពីរនេះ ។ លុះថ្ងៃបន្ទាប់មក ខ្ញុំបានទទួលអ៊ីមែលមួយទៀត ដែលចាប់ផ្ដើមថា ៖ « នោះគឺជារឿងរបស់ឪពុកខ្ញុំដែរ » ។ អ៊ីមែលនោះ គឺបានទទួលពីប្រធានស្តេកម្នាក់ បានប្រាប់ពីរបៀបដែលឪពុករបស់គាត់ ត្រូវបានអញ្ជើញឲ្យបម្រើនៅក្នុងសាសនាចក្រ ថ្វីបើគាត់មិនសកម្ម ហើយមាននូវទម្លាប់ខ្លះដែលត្រូវការផ្លាស់ប្ដូរក្ដី ។ គាត់បានទទួលការអញ្ជើញនោះ ហើយនៅក្នុង

ដំណើរការនោះ គាត់បានប្រែចិត្ត ហើយនៅទីបំផុត គាត់ក៏បានបម្រើជាប្រធានស្តេក រួចហើយបជាប្រធានបេសកកម្ម ហើយបានចាក់គ្រឹះសម្រាប់កូនចៅរបស់គាត់ ឲ្យធ្វើជាសមាជិកសាសនាចក្រដ៏ស្មោះត្រង់ ។

ពីរបីសប្តាហ៍ក្រោយមក ខ្ញុំបានប្រាប់រឿងទាំងបី នៅក្នុងសន្និសីទស្តេកមួយទៀត ។ បន្ទាប់ពី ការប្រជុំនោះ មានបុរសម្នាក់បានមកជួបខ្ញុំ ហើយបានប្រាប់ខ្ញុំថា នោះមិនមែន ជារឿងរបស់ឪពុកគាត់ទេ ។ វាជារឿងរបស់គាត់ផ្ទាល់ ។ គាត់បានប្រាប់ខ្ញុំពីព្រឹត្តិការណ៍ដែលនាំគាត់ឲ្យប្រែចិត្ត ហើយត្រឡប់មកចូលរួមដ៏ពេញលេញក្នុងសាសនាចក្រវិញ ។ ហើយដំណើររឿងនោះបានបន្តទៀតថា ៖ កាលខ្ញុំ បាននាំយកការអំពាវនាវឲ្យសង្គ្រោះដល់សមាជិកមិនសូវសកម្ម នោះខ្ញុំបានឮរឿងមួយហើយមួយទៀត ពីអ្នកដែលឆ្លើយតបនឹងការអញ្ជើញឲ្យត្រឡប់មក ហើយផ្លាស់ប្តូរជីវិតខ្លួនវិញ ។ ខ្ញុំបានឮរឿងនៃការប្រោសលោះជាច្រើន ។

ថ្វីបើយើងមិនអាចបង់សងព្រះប្រោសលោះ នូវអ្វីដែលទ្រង់បានបង់ជំនួសយើងក្តី ក៏ផែនការនៃ សេចក្តីប្រោសលោះអំពាវនាវដល់យើងឲ្យខិតខំអស់ពីលទ្ធភាពរបស់យើង ដើម្បី ប្រែចចិត្តដោយពេញលេញ ហើយធ្វើតាមព្រះហឫទ័យរបស់ព្រះ ។ សាវក អូសុន អែហ្វ វិតនី បានសរសេរថា ៖

«ព្រះសង្គ្រោះ ព្រះប្រោសលោះនៃព្រលឹងរបស់ខ្ញុំ ដែលព្រះហស្តដ៏មហាអស្ចារ្យរបស់ទ្រង់ បានប្រោសលោះខ្ញុំ ដែលអំណាចដ៏ខ្លាំងក្លារបស់ទ្រង់បានលើកខ្ញុំឡើង ហើយដែលបំពេញកែវដ៏ល្វីងជូរចត់របស់ខ្ញុំដោយភាពផ្អែមល្ហែម ! ឱ ព្រះដ៏សន្តោសប្រណីនៃអ៊ីស្រាអែល គ្មាននរណាអាចវាស់វែងពីអំណរគុណរបស់ខ្ញុំបានឡើយ ។

« ខ្ញុំមិនអាចបង់សងទ្រង់វិញបានឡើយ តែទូលបង្គំអាចស្រឡាញ់ទ្រង់ ។ ព្រះបន្ទូលដ៏បរិសុទ្ធរបស់ទ្រង់ គឺជាសេចក្តីរីករាយ សេចក្តីអំណរនៃទូលបង្គំនៅពេលថ្ងៃ និងការសុបិនរបស់ខ្ញុំនៅពេលយប់ ? រួចហើយសូមឲ្យបបូរមាត់ទូលបង្គំបន្លឺឡើងថា ជីវិតទូលបង្គំជាការឆ្លុះបញ្ចាំងនៃព្រះហឫទ័យរបស់ទ្រង់ » ( « Savior, Redeemer of My Soul » *Hymns* ទំព័រ 112 ) ។

ខ្ញុំសូមថ្លែងទីបន្ទាល់ពីអំណាចនៃដង្វាយធួនរបស់ព្រះគ្រីស្ទ ។ ពេលយើងប្រែចិត្ត ហើយមករកទ្រង់ យើងអាចទទួលគ្រប់អស់ទាំងពរនៃជិវិតដ៏អស់កល្ប ។ នោះជាអ្វីដែលយើងត្រូវធ្វើ ដោយទទួលរឿងនៃការប្រោសលោះរបស់យើងផ្ទាល់ នេះជាការអធិស្ឋានរបស់ខ្ញុំ ក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។